# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី១១

## លើឯកសារអាជ្ញាប័ណ្ណរួម លេខ ០០១ ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២

## របស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា

## សម្រាប់ការដកតំបន់ចែកចាយ និងពង្រីកតំបន់ចែកចាយ

# DECISION ON ELEVENTH REVISION

**TO THE LICENSE DOCUMENT No. 001 LD DATED FEBRUARY 01, 2002**

**ISSUED TO ELECTRICITÉ DU CAMBODGE**

**For Withdrawing and Expanding Distribution Area of**

**Electricité Du Cambodge**

ថ្ងៃទី ខែ ឆ្នាំ២០១០

, 2010

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ : -១០-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី១១ លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០០១ ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២ សម្រាប់ក្រុមហ៊ុនអគ្គិសនីកម្ពុជា

# DECISION ON ELEVENTH REVISION to the License Document No. 001 LD dated February 01, 2002 issued to Electricité Du Cambodge

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣០ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 30 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated February 2, 2001.

-យោងឯកសារអាជ្ញាប័ណ្ណរួមរបស់អគ្គិសនីកម្ពុជា លេខ ០០១ ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២

-Refer to the Consolidated License Document of Electricité du Cambodge No.001 dated February 01, 2002.

-យោងលិខិតលេខ ៤៨៦២ អក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ និងលិខិត លេខ៤៩០៧ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ របស់អគ្គិសនីកម្ពុជា

-Refer to the requested letter of EDC No. 4862 dated October 27, 2009 and No. 4907 dated October 30, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០១០ ដល់ថ្ងៃ ទី ខែ ឆ្នាំ២០១០

-In accordance with the consultation with concerned parties and public, made from , 2010 to , 2010

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី នៅថ្ងៃទី ខែ ឆ្នាំ២០១០

-In accordance with the decision of Electricity Authority of Cambodia's Session No. dated , 2010.

# សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ ១**<br>ចេញសេចក្តីសម្រេចបន្ថែមលើឯកសារអាជ្ញាប័ណ្ណលេខ ០០១ ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២ ដែលបានផ្តល់ជូន **"អគ្គិសនីកម្ពុជា"** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") ដើម្បីអនុញ្ញាតឱ្យអគ្គិសនីកម្ពុជា ដកតំបន់ចែកចាយអគ្គិសនី និងពង្រីកតំបន់ចែកចាយអគ្គិសនីដូចខាងក្រោម ៖ | **Article 1**<br>To issue additional decision on the license document No. 001 LD dated February 01, 2002 granted to state-owned enterprise "Electricité du Cambodge" (herein after referred to as "Licensee") to allow licensee to withdraw and expand distribution areas as stated below: |
| ១. ដកតំបន់មួយផ្នែកនៃឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល សម្រាប់តំបន់ចែកចាយរាជធានីភ្នំពេញ និងតំបន់ជុំវិញ ហើយប្រគល់ឱ្យក្រុមហ៊ុន អិល អឹម ខេ ធ្វើសេវាកម្មចែកចាយវិញ (មានបង្ហាញក្នុងផែនទីភ្ជាប់លេខ 001LD-Map-EDC-PNH-Revised-11-2010 ) | 1. To withdraw a part of Khum Prek Kampeus, Kandal Stoeung Districts, Kandal Province from authorised distribution area of Phnom Penh and its surrounding and let LMK Co., Ltd to distribute in the area (as shown in the attached map No. 001LD-Map-EDC-PNH-Revised-11-2010). |
| ២. បន្ថែមតំបន់មួយផ្នែកនៃឃុំក្បាលកោះ និងឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល សម្រាប់តំបន់ចែកចាយរាជធានីភ្នំពេញ និងតំបន់ជុំវិញ ឱ្យអគ្គិសនីកម្ពុជាធ្វើសេវាកម្មចែកចាយ (មានបង្ហាញក្នុងផែនទីភ្ជាប់លេខ 001LD-Map-EDC-PNH-Revised-11-2010 ) ។ | 2. To add a part of Khum Kbal Koh and Khum Phum Thom, Kean svay Districts, Kandal Province for authorised distribution area of Phnom Penh and its surrounding to Electricité du Cambodge (as shown in the attached map No. 001LD-Map-EDC-PNH-Revised-11-2010). |
| **ប្រការ ២**<br>ឧបសម្ព័ន្ធទី២ ដែលភ្ជាប់ជាមួយឯកសារអាជ្ញាប័ណ្ណលេខ ០០១ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី២ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 2 of the license document No. 001 LD is replaced by the new revised schedule2 attached here with. |
| **ប្រការ ៣**<br>សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០០១ឯអ ។ | **Article 3**<br>This decision and the attached Schedule are the part of license document No. 001 LD. |
| **ប្រការ ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណ លេខ ០០១ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 4**<br>The other contents and conditions of the license document No. 001 LD shall remain unaltered and in force. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០០១ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០០១ ឯអ ដែលតម្កល់ទុក មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 001 LD has been deposited in order that the deposited license document No. 001 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១០

, 2010

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី២
# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី នាថ្ងៃទី ខែ ឆ្នាំ២០១០

# SCHEDULE 2

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC No. DATED , 2010

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី ដែលអគ្គិសនីកម្ពុជាមានសិទ្ធិផ្តល់សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនី មានដូចខាងក្រោម : | 1. The authorizes distribution Areas, where EDC have the right to provide the electricity distribution and supply services are comprising of: |
| (ក)–តំបន់ចែកចាយរាជធានីភ្នំពេញ និងតំបន់ជុំវិញ ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ 001LD-Map-EDC-PNH-Revised-11-2010 | (a) Phnom Penh and its surrounding Distribution Area, which is determined by the boundary map No. 001LD-Map-EDC-PNH-Revised-11-2010. |
| (ខ)–តំបន់ចែកចាយក្រុងព្រះសីហនុ ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-SHV-D-Map | (b) Sihanoukville Distribution Area, which is determined by the boundary map No. EDC-SHV-D-Map |
| (គ)–តំបន់ចែកចាយទីរួមខេត្តសៀមរាប ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-SRP-D-map-Revised2-2007 | (c) Siem Reap town Distribution Area, which is determined by the boundary map No. EDC-SRP-D-map-Revised2-2007 |
| (ឃ)–តំបន់ចែកចាយទីរួមខេត្តកំពង់ចាម ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-KCM-D-Map-Revised-1 | (d) Kampong Cham town Distribution Area, which is determined by the boundary map No. EDC-KCM-D-Map Revised-1 |
| (ង)–តំបន់ចែកចាយទីរួមខេត្តបាត់ដំបង ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ 001LD-Map-EDC-BBG-D-Revised-9-2008 | (e) Battambang town Distribution Area, which is determined by the boundary map No. 001LD-Map-EDC-BBG-D-Revised-9-2008 |
| (ច)–តំបន់ចែកចាយទីរួមខេត្តតាកែវ ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-TKO-D-Map-Revised-1 | (f) Takeo town Distribution Area, which is determined by the boundary map No. EDC-TKO-D-Map-Revised-1 |
| (ឆ)–តំបន់ចែកចាយទីរួមខេត្តបន្ទាយមានជ័យ ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-BTM-D-Map Revised-1 | (g) Banteay Meanchey town Distribution Area, which is determined by the boundary map No. EDC-BTM-D-Map-Revised-1 |
| (ជ)–តំបន់ចែកចាយទីរួមខេត្តកំពត ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ 001LD-Map-EDC-KP-Revised-8-2008 | (h) Kampot town Distribution Area, which is determined by the boundary map No. 001LD-Map-EDC-KP-Revised-8-2008. |
| (ឈ)–តំបន់ចែកចាយទីរួមខេត្តស្វាយរៀង ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ 001LD-Map-EDC-SVR-D-Revision-9-2008 | (i) Svay Rieng town Distribution Area, which is determined by the boundary map No. 001LD-Map-EDC-SVR-D-Revision-9-2008 |
| (ញ)–តំបន់ចែកចាយទីរួមខេត្តព្រៃវែង ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-PRV-D-Map | (j) Prey Veng town Distribution Area, which is determined by the boundary map No. EDC-SVR-D-Map |
| (ដ)–តំបន់ចែកចាយទីរួមខេត្តកំពង់ស្ពឺ ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ EDC-KSP-D-Map | (k) Kampong Speu town Distribution Area, which is determined by the boundary map No. EDC-KSP-D-Map |
| (ឋ)–តំបន់ចែកចាយទីរួមខេត្តរតនគីរី ដែលកំណត់ដោយផែនទីកំណត់ | (l) Ratanakiri town Distribution Area, which is determined by |

| | |
|---|---|
| ព្រំប្រទល់ លេខ EDC-RNK-D-Map | the boundary map No. EDC-RNK-D-Map |
| (ឌ)-តំបន់ចែកចាយទីរួមខេត្តស្ទឹងត្រែង ដែលមានព្រំដីជាប់គ្នា និង កំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ STR-D-Map | (m) Steung Treng town Distribution Area, which is the fixed contiguous territory and determined by the boundary maps No. STR-D-Map |
| (ឍ)-តំបន់ចែកចាយទីរួមស្រុកពញាក្រែកនិងមេមត់ ដែលកំណត់ដោយ ផែនទីកំណត់ព្រំប្រទល់ លេខ EDC-KR&M-D-Map | (n) Ponhea Krek and Memot district Distribution Area, which is determined by the boundary map No. EDC-KR&M-D-Map |
| (ណ)-តំបន់ចែកចាយឃុំបាវិត ដែលកំណត់ដោយផែនទីកំណត់ព្រំប្រទល់លេខ EDC-BVT-D-Map-Revived-1 | (o) Bavit Distribution Area, which is determined by the boundary map No. EDC-BVT-D-Map-Revived-1 |
| (ត)-តំបន់ចែកចាយទីរួមស្រុកកំពង់ត្រាច ឃុំឫស្សីស្រុកខាងលិច ឃុំកំពង់ត្រាចខាងកើត និង ឃុំកន្ធោរខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត EDC-KGTr-D-Map-Revised-1 | (p) Kompong Trach district Town, Khum Oeuseysrok Khanglech Khum Kompong Trach Khangkeut and Khum Kanthor Khanglech, Kompong Trach District, Kompot Province Distribution Area, which is determined by the boundary map No. EDC-KGTr-D-Map Revised-1. |
| ២- អាជ្ញាប័ណ្ណចែកចាយដែលផ្តល់ឱ្យតាមឯកសារនេះ ផ្តល់សិទ្ធិឱ្យអគ្គិសនីកម្ពុជា អាចស្នើសុំពង្រីក ឬស្នើសុំបន្ថែមតំបន់ចែកចាយអគ្គិសនីថែមទៀត យោងតាមគំរោងអភិវឌ្ឍន៍របស់ខ្លួន។ | 2. Distribution License granted by this document provides the right to EDC to apply for the extension or the additional distribution area in accordance with its development plan. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើ អគ្គិសនីកម្ពុជាមានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអគ្គិសនីកម្ពុជាត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី២នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ។ | 3. Under this license, if EDC intends to request the extension or the additional distribution areas then EDC shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 2 shall be revised and attached with that authorization. |